**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ....៩០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយ ចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# សម្រេច

**មាត្រាមួយ .-**

មាត្រា៧នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា៧ .- ថ្មី**

ប្រាក់ឧបត្ថម្ភចំពោះទារកកំព្រា កុមារកំព្រា កុមារនិងយុវកុមាររងគ្រោះដោយការប្រើបំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់នឹងច្បាប់ ជនរងគ្រោះដោយការប្រើបំពានសារធាតុញៀនខុសច្បាប់ ជនរងគ្រោះដោយការជួញដូរមនុស្ស ជនពិការ ជនអនាថា និងជនចាស់ជរាគ្មានទីពឹង មានដូចខាងក្រោម៖

| ល.រ. | ប្រភេទមុខសញ្ញា និងកម្រិតអាយុ | ចំនួនឯកតាក្នុង១នាក់ | ប្រាក់ឧបត្ថម្ភ | ប្រភេទមុខចំណាយ | កំណត់សម្គាល់ |
|---|---|---|---|---|---|
| ១ | ទារកកំព្រា កុមារកំព្រា ទារក កុមារពិការធ្ងន់ធ្ងរ មានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគឬមានជំងឺអេដស៍(HIV/AIDS) | | | | |
| ១.១ | ទារកអាយុ២ឆ្នាំចុះ | ១ខែ | ១៥០ ០០០៛ | ទឹកដោះគោ | |
| | | ១ដងក្នុង១ឆ្នាំ | ១២០ ០០០៛ | សម្លៀកបំពាក់ សម្ភារៈដំណេក អនាម័យ និងព្យាបាល | ទទួលពេលដើមឆ្នាំ |
| ១.២ | កុមារអាយុលើសពី២ឆ្នាំ | ១ខែ | ១៥០ ០០០៛ | ម្ហូបអាហារ | |
| | | ១ដងក្នុង១ឆ្នាំ | ១២០ ០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល | ទទួលពេលដើមឆ្នាំ |
| ១.៣ | ទារក កុមារពិការធ្ងន់ធ្ងរ មានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ (HIV/AIDS) | ១ខែ | ២០ ០០០៛ | បំប៉នសុខភាព | |
| ១.៤ | ទារក កុមារអាយុ៥ឆ្នាំចុះ ទទួលមរណភាព | ១ដងគត់ | ២៧០ ០០០៛ | រៀបចំពិធីបុណ្យសព | |
| ១.៥ | កុមារអាយុលើសពី៥ឆ្នាំឡើង ទទួលមរណភាព | ១ដងគត់ | ៥៤០ ០០០៛ | រៀបចំពិធីបុណ្យសព | |
| ១.៦ | អាយុពី១៨ឆ្នាំ ឡើង | ១ដងគត់ | ១ ០៨០ ០០០៛ | សមាហរណកម | |
| ២ | កុមារនិងយុវកុមាររងគ្រោះដោយការប្រើបំពានសារធាតុញៀនខុសច្បាប់ | | | | |

| | | | | | |
|---|---|---|---|---|---|
| | និងជនរងគ្រោះដោយការប្រើបំពានសារធាតុញៀនខុសច្បាប់ | | | | |
| ២.១ | កុមារនិងយុវកុមារអាយុពី៧ឆ្នាំ ដល់ក្រោម១៨ឆ្នាំ និងជនរងគ្រោះដោយការប្រើបំពានសារធាតុញៀនខុសច្បាប់ | ១ខែ | ១៥០ ០០០៛ | ម្ហូបអាហារ | |
| | | ១ឆ្នាំ | ១២០ ០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ថ្នះបាយ អនាម័យ និងព្យាបាល | ទទួលពេលដើមឆ្នាំ |
| | | ១វគ្គ | ៣៩០ ០០០៛ | បណ្ដុះបណ្ដាលមុខជំនាញវិជ្ជាជីវៈ | រយៈពេល៣ខែ |
| | | ១ដងគត់ | ២២៥ ០០០៛ | សមាហរណកម្ម | |
| ៣ | ជនរងគ្រោះដោយការជួញដូរមនុស្ស | | | | |
| ៣.១ | ជនរងគ្រោះដោយការជួញដូរមនុស្ស | ១ខែ | ១៥០ ០០០៛ | ម្ហូបអាហារ | |
| | | ១ឆ្នាំ | ១២០ ០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ថ្នះបាយ អនាម័យ និងព្យាបាល | ទទួលពេលដើមឆ្នាំ |
| | | ១វគ្គ | ៣៩០ ០០០៛ | បណ្ដុះបណ្ដាលមុខជំនាញវិជ្ជាជីវៈ | រយៈពេលខ្លី ៣ខែ |
| | | ១ដងគត់ | ៨១០ ០០០៛ | សមាហរណកម្ម | |
| ៤ | ជនពិការ ជនអនាថា និងជនចាស់ជរាគ្មានទីពឹង | | | | |
| ៤.១ | ជនពិការ ជនអនាថា និងជនចាស់ជរាគ្មានទីពឹង | ១ខែ | ១៥០ ០០០៛ | ម្ហូបអាហារ | |
| | | ១ឆ្នាំ | ១២០ ០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ថ្នះបាយ អនាម័យ និងព្យាបាល | ទទួលពេលដើមឆ្នាំ |
| ៤.២ | ជនពិការបាត់បង់សមត្ថភាពពលកម្មធ្ងន់ធ្ងរ ជនអនាថា ជនចាស់ជរាគ្មានទីពឹង និងជនពិការមានជំងឺអេដស៍(AIDS) | ១ខែ | ២០ ០០០៛ | បំប៉នសុខភាព | |
| ៤.៣ | ជនពិការអនាថាដែលមានជំងឺអេដស៍(AIDS) | ១វគ្គ | ៣៩០ ០០០៛ | បណ្ដុះបណ្ដាលមុខជំនាញវិជ្ជាជីវៈ | រយៈពេលខ្លី ៣ខែ |
| ៤.៤ | ជនពិការ ជនអនាថា និងជនចាស់ជរាគ្មានទីពឹងទទួលមរណភាព | ១ដងគត់ | ៥៤០ ០០០៛ | រៀបចំពិធីបុណ្យសព | |

| | | | | | |
|---|---|---|---|---|---|
| ៤.៥ | ជនពិការ ជនអនាថា និងជនចាស់ជរាគ្មានទីពឹង | ១ដងគត់ | ៨១០ ០០០៛ | សមាហរណកម្ម | |

ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៥ តទៅ។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**វង សូត**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ